ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ លើកទី២ និងកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់ ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ លើកទី២ និងកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

## ១. កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ លើកទី២

កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ លើកទី២ បានពិនិត្យវឌ្ឍនភាពនៃការអនុវត្តក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ (២០២៤-២០២៨) និងបានពិភាក្សាពីទិសដៅអនាគត ដើម្បីដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពដែលកំពុងកើតឡើង។ ថ្នាក់ដឹកនាំបានបញ្ជាក់សារជាថ្មីពីសារៈសំខាន់នៃការបង្កើនលំហូរពាណិជ្ជកម្ម និងការវិនិយោគ ជាពិសេសតាមរយៈការពង្រឹងទំនាក់ទំនងរវាងសហគមន៍ធុរកិច្ច រួមទាំងការជំរុញកិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាធុរកិច្ចអាស៊ាន (ASEAN-BAC) និងសហព័ន្ធសភានៃក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំក៏បានពិភាក្សាលើការសិក្សាពីលទ្ធភាពក្នុងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រផងដែរ។

**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីតួនាទីរបស់ពាណិជ្ជកម្ម និងការវិនិយោគ ក៏ដូចជាប្រព័ន្ធពាណិជ្ជកម្មសេរី និងបើកចំហដែលផ្អែកលើច្បាប់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងរយៈពេលវែង។ **សម្ដេចធិបតី** បានគូសបញ្ជាក់ពីតម្រូវការលើកកម្ពស់ភាពធន់ ការប្រកួតប្រជែង និងផលិតភាពរបស់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

(MSMEs)។ ថ្នាក់ដឹកនាំបានកត់សម្គាល់ពីអត្ថ-ប្រយោជន៍មួយចំនួន ដែលបំពេញឱ្យគ្នាទៅវិញទៅមករវាងអាស៊ាន និងក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ ជាពិសេសលើវិស័យយុទ្ធសាស្ត្រដូចជាថាមពល និងសន្តិសុខស្បៀង រួមទាំងបណ្តាញអគ្គិសនីអាស៊ាន និងឧស្សាហកម្មហាឡាល។

ថ្នាក់ដឹកនាំក៏បានផ្លាស់ប្តូរទស្សនៈពីបញ្ហាតំបន់ និងសាកល ដោយបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់របស់យើង។ គូសបញ្ជាក់ពីស្មារតីនៃកិច្ចប្រជុំកំពូល **សម្តេចធិបតី** បានអំពាវនាវឱ្យមានបទឈប់បាញ់ជាអចិន្ត្រៃយ៍នៅហ្គាហ្សា ដោយអនុលោមពេញលេញតាមច្បាប់មនុស្សធម៌អន្តរជាតិ និងសូមបញ្ជាក់សារជាថ្មីនូវការគាំទ្រចំពោះដំណោះស្រាយរដ្ឋពីរ ដោយផ្អែកលើច្បាប់អន្តរជាតិ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។

## ២. កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន

កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន បានប្រព្រឹត្តទៅក្រោមមូលបទ «ការរួមបញ្ចូលគ្នានៃកាលានុវត្តភាពសេដ្ឋកិច្ចឆ្ពោះទៅរកវិបុលភាពរួម» ក្នុងគោលបំណងពង្រឹងភាពធន់សេដ្ឋកិច្ច ជំរុញកិច្ចសហប្រតិបត្តិការពហុវិស័យ និងលើកកម្ពស់វិបុលភាពរួម។ ថ្នាក់ដឹកនាំបានផ្លាស់ប្តូរមតិគ្នាលើការវិវត្តសំខាន់ៗក្នុងតំបន់ទាំងបី និងបានស្វែងរកវិស័យនៃកិច្ចសហ-ប្រតិបត្តិការដែលមានសក្តានុពល ដែលរួមមានពាណិជ្ជកម្មនិងការវិនិយោគ សេដ្ឋកិច្ចឌីជីថល សន្តិសុខស្បៀងនិងថាមពល ទេសចរណ៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ និងការផ្លាស់ប្តូរប្រជាជននិងប្រជាជន វប្បធម៌ និងការអប់រំ។

ដោយក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រជាដៃគូពាណិជ្ជកម្មធំជាងគេទី៦ របស់អាស៊ាន **សម្តេចធិបតី** បានស្នើឱ្យអាស៊ាន និងក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ ពន្លឿនការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីស៊ីជម្រៅ ដើម្បីពង្រីកទីផ្សារ លើកកម្ពស់ការតភ្ជាប់ទំនិញ សេវាកម្ម និងការវិនិយោគ និងជំរុញការធ្វើសុខដុមនីកម្មស្តង់ដារ និងការសម្របសម្រួលពាណិជ្ជកម្ម។

**សម្តេចធិបតី** បានគូសបញ្ជាក់ផងដែរថា ប្រទេសចិននៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍរបស់អាស៊ាន ដែលជាដៃគូពាណិជ្ជកម្មធំបំផុតរបស់តំបន់ និងជាប្រភពនៃការវិនិយោគផ្ទាល់ពីបរទេសធំទីពីរ។ **សម្តេចធិបតី** បានកោតសរសើរដល់ការបញ្ចប់ដោយជោគជ័យនូវការដំឡើងកម្រិតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ (ACFTA 3.0) និងទន្ទឹងរកចាំការចុះហត្ថលេខានាពេលចុងឆ្នាំនេះ។ ការដំឡើងកម្រិតនេះនឹងគាំទ្រទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន-ចិនបន្ថែមទៀត ជាពិសេសលើវិស័យមួយចំនួនដូចជាសេដ្ឋកិច្ចឌីជីថល សេដ្ឋកិច្ចបៃតង និងការតភ្ជាប់ខ្សែសង្វាក់ផ្គត់ផ្គង់ជាដើម។

**សម្តេចធិបតី** បានគូសបញ្ជាក់ថា ការចូលរួមរបស់ប្រទេសចិនក្នុងគំនិតផ្តួចផ្តើមត្រីភាគីនេះ បានបង្កើនឥទ្ធិពល និងសារៈសំខាន់ជាយុទ្ធសាស្ត្រយ៉ាងខ្លាំងបន្ថែមទៀត។ ជាមួយគ្នានេះផងដែរ អាស៊ាន ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ និងចិន អាចប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បី

គាំទ្រដល់ការផ្លាស់ប្តូរ ថាមពល ពាណិជ្ជកម្មឌីជីថល បច្ចេកវិទ្យាហិរញ្ញវត្ថុ និងវិស័យថ្មីៗផ្សេងទៀត។ **សម្តេចធិបតី** ក៏បានលើកទឹកចិត្តឱ្យស្វែងរកមធ្យោបាយក្នុងការកៀរគរធនធាន រួមទាំងតាមរយៈគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាបណ្តាញថាមពលអាស៊ាន និងគំនិតផ្តួចផ្តើមការតភ្ជាប់ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

**សម្តេចធិបតី** បានសង្កត់ធ្ងន់ថា កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន គឺជាការបោះជំហានដ៏សំខាន់ឆ្ពោះទៅការកសាងភាពជាដៃគូដែលមានភាពធន់បរិយាបន្ន និងត្រៀមរួចលក្ខណៈសម្រាប់អនាគត។ **សម្តេចធិបតី** បានបញ្ជាក់ថា គំរូកិច្ចសហប្រតិបត្តិការនេះមានសក្តានុពលក្នុងការនាំមកនូវផលប្រយោជន៍ជារូបវន្តដល់ប្រជាជន និងជាគំរូសម្រាប់ការចូលរួមរបស់អាស៊ានជាមួយដៃគូខាងក្រៅកាន់តែច្រើនឡើង ក្រោមរបៀបវារៈអាស៊ានសកល។ ក្នុងន័យនេះ **សម្តេចធិបតី** បានស្វាគមន៍ការអនុម័តសេចក្តីប្រកាសរួម ស្តីពីកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ-ចិន។

## ៣. ជំនួបទ្វេភាគី

ស្របពេលនឹងកិច្ចប្រជុំកំពូលនេះ **សម្តេចធិបតី** ក៏បានជួបពិភាក្សាការងារទ្វេភាគីជាមួយថ្នាក់ដឹកនាំរបស់ប្រទេសចិន ម៉ាឡេស៊ី ហ្វីលីពីន អូម៉ង់ បារ៉ែន និងកូវ៉ែត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងទ្វេភាគី ព្រមទាំងបានផ្លាស់ប្តូរទស្សនៈលើបញ្ហាដែលជាផលប្រយោជន៍រួម។ បន្ថែមពីលើនេះ **សម្តេចធិបតី** បានអញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់តបតាមការអញ្ជើញរបស់**ព្រះចៅស៊ុលតង់ អ៊ីប្រាហ៊ីម ព្រះមហាក្សត្រម៉ាឡេស៊ី** ផងដែរ។ ទន្ទឹមនឹងនេះ **សម្តេចធិបតី** បានទទួលជំនួបសម្តែងការគួរសមពីវិស័យឯកជន ដើម្បីពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងធុរកិច្ច ពាណិជ្ជកម្ម និងកាលានុវត្តភាពនៃការវិនិយោគ៕

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥